# មេរៀនទី ១៥២:
# ព្រះសន្យាថានឹងស្តារអ៊ីស្រាអែលឡើងវិញបន្ទាប់ពីការនិរទេសខ្លួន

## យេរេមា ២៩:៤-១៤

| **គោលបំណង៖** ព្រះមានផែនការល្អសំរាប់យើង។ |
|---|

| **ខគម្ពីរចងចាំ៖ យេរាមា ២៩:១១** *“ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្តី ដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេគឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុតឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម។”* |
|---|

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ប្រសិនបើយើងរស់នៅជាមួយព្រះយេស៊ូវជារៀងរាល់ថ្ងៃ ហើយរីកចម្រើនក្នុងសេចក្តីជំនឿរបស់យើង នោះព្រះបានផ្តល់ឱ្យយើងនូវការណែនាំផ្លូវ និងការកែតម្រូវសម្រាប់ជីវិតរបស់យើង។ ពេលដែលយើងឆ្លើយតបទៅនឹងការដឹកនាំរបស់ព្រះអង្គ យើងនឹងមានអំណរជាមួយនឹងសន្តិភាព និងសុវត្ថិភាពដែលមានតែព្រះទេ ដែលអាចផ្តល់ឲ្យយើងបាន។ ដូចជាជនជាតិយូដាបានរស់នៅជាឈ្លើយក្រោមការគ្រប់គ្រងរបស់បាប៊ីឡូន វាហាក់ដូចជាគ្មានសង្ឃឹមសម្រាប់ពួកគេ។ ប៉ុន្តែ ព្រះបានប្រទានសេចក្តីសង្ឃឹមដល់ពួកគេដោយមានបន្ទូលថា ពួកគេនឹងត្រឡប់ទៅស្រុកយូដាវិញក្រោយ៧០ឆ្នាំ។ តើអ្នកកំពុងនៅកន្លែងណាក្នុងដំណើរជីវិតខាងព្រលឹងវិញ្ញាណរបស់អ្នក? តើអ្នកនៅផ្ទះ ឬនៅជាឈ្លើយ? ឆ្លុះបញ្ចាំងដំណើរជីវិតរបស់អ្នកជាមួយព្រះ ហើយទូលសុំព្រះអង្គឲ្យជួយបង្ហាញផ្លូវ និងកែតម្រូវជីវិតរបស់អ្នកនៅថ្ងៃនេះ។

| **ចំរៀង៖** | ១. ព្រះទ្រង់ល្អណាស់ | ២. ព្រះអម្ចាស់យើងល្អណាស់ | ៣. ទ្រង់មិនដែលខាន |
|---|---|---|---|

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

| **៣. ល្បែងកំសាន្ត** «ដណ្តើមស្លឹកគ្រាប់» |
|---|

**សម្ភារៈដែលត្រូវការ៖** ស្លឹកគ្រាប់មួយចំនួនធំ






១.ឱ្យកុមារឈរជាពីរជួរទល់មុខគ្នា។

២. គ្រូត្រូវដាក់ស្លឹកគ្រាប់ ៤គ្រាប់នៅលើតុដួ សម្រាប់ដៃគូរនីមួយៗ។

៣. គ្រូត្រូវនិយាយថា “ក្បាល ស្មា ជង្គង់ ចុងជើង” ប៉ុន្តែនៅពេលដែលគ្រូនិយាយពាក្យ “ស្លឹកគ្រាប់” ។ ដូច្នេះដៃគូរត្រូវដណ្តើមស្លឹកគ្រាប់គ្នា។

៤. កុមារណាដែលមិនអាចយកស្លឹកគ្រាប់នោះបាន គេមិនអាចបន្តលេងល្បែងនេះបានទេ។

៥. អ្នកឈ្នះទាំងអស់ត្រូវឈរជាជួរដោយចាប់ដៃគូរ និងលេងម្តងទៀត។

៦. លេងល្បែងនេះរហូតនៅសល់កុមារតែម្នាក់ជាអ្នកឈ្នះ។

៧.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា គឺដូចជាអ្នកឈ្នះល្បែងនេះអីចឹង យើងត្រូវតែផ្ដោតអារម្មណ៍ជានិច្ច ប្រសិនបើយើងផ្ដោតលើព្រះ នោះទ្រង់នឹងបង្ហាញយើងពីផែនការដ៏ល្អដែលទ្រង់មានសម្រាប់យើង។

## ៤. ការណែនាំមេរៀន

បន្ទាប់ពីថ្វាយបង្គំនៅព្រះវិហាររួច តើអ្នកមានគម្រោងធ្វើអ្វី? តើអ្នកមានគំរោងទៅផ្ទះវិញ ឬទៅលេងជាមួយមិត្តភក្តិរបស់អ្នក? តើអ្នកមានគំរោងអ្វីខ្លះសំរាប់អនាគតរបស់អ្នក? តើអ្នកចង់ក្លាយជាប៉ូលីស? ជាគ្រូបង្រៀន? ជាគ្រូពេទ្យ? ជាកសិករមែនទេ? ពេលខ្លះវាជាការពិបាកក្នុងការបង្កើតគំរោងសំរាប់អនាគត ពីព្រោះអ្នកមិនអាចមើលឃើញពីអនាគតទេ។ ប៉ុន្តែព្រះជ្រាបដឹងពីអនាគតរបស់យើង ហើយព្រះអង្គមានផែនការដ៏ល្អសំរាប់យើង! ចូរយើងរៀនអំពីផែនការដ៏ល្អដែលព្រះមានសំរាប់ជនជាតិយូដា!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះបានប្រទាននូវច្បាប់យ៉ាងពិសេសសម្រាប់ជនជាតិយូដាដើម្បីឱ្យពួកគេប្រព្រឹត្តតាម ពីព្រោះព្រះអង្គស្រឡាញ់ និងចង់ជួយពួកគេឱ្យចេញឆ្ងាយពីការជ្រើសរើសអ្វីដែលមិនត្រឹមត្រូវ។ ប៉ុន្តែជនជាតិយូដាបានធ្វើខុសនឹងច្បាប់ទាំងនោះ ហើយពួកគេបានសំរេចចិត្តធ្វើអ្វីដែលពួកគេចង់ធ្វើតាមផ្លូវរបស់ខ្លួនទៅវិញ។ ពួកគេមិនស្តាប់បង្គាប់ព្រះ ហើយព្រះអង្គបានព្រមានពួកគេជាច្រើនដង។ ទ្រង់បានមានបន្ទូលថា“ឯងត្រូវស្តាប់បង្គាប់អញ បើឯងមិនស្តាប់បង្គាប់អញ អញនឹងដាក់ទោសឯង។” ព្រះបានផ្តល់ឱកាសដល់ជនជាតិយូដាជាច្រើនដង ដើម្បីឱ្យពួកគេទទួលស្គាល់កំហុសរបស់ពួកគេ ហើយចាប់ផ្តើមស្តាប់បង្គាប់ព្រះឡើងវិញ ប៉ុន្តែពួកគេនៅតែជ្រើសរើសមិនស្តាប់បង្គាប់ព្រះដដែល។

នៅទីបំផុតជនជាតិយូដាត្រូវបានដាក់ទោស។ ដោយមានប្រទេសដទៃបានចាប់ពួកគេធ្វើជាឈ្លើយ ហើយបញ្ជូនពួកគេទៅកន្លែងមួយហៅថាស្រុកបាប៊ីឡូន។ ពួកគេមិនចង់ចាកចេញពីផ្ទះរបស់ពួកគេទេ ប៉ុន្តែពួកគេត្រូវតែទៅ។ ដូច្នេះពួកគេបានរៀបចំសំពាយរបស់ពួកគេហើយចេញដំណើរទៅ។ ពួកគេរស់នៅស្រុកបាប៊ីឡូនអស់រយៈពេល ៧០ឆ្នាំជាង! នេះជារយៈពេលដ៏យូរ ដែលពួកគេរស់នៅឆ្ងាយពីផ្ទះរបស់ខ្លួន! ប៉ុន្តែព្រះមានផែនការពិសេសសំរាប់ពួកគេ។ ទោះបីជាពួកគេមិនស្តាប់បង្គាប់ទ្រង់ក៏ដោយក៏ព្រះនៅតែស្រឡាញ់ពួកគេ ដូចជាទ្រង់ស្រឡាញ់អ្នកដែរ។

ព្រះគម្ពីរបានប្រាប់យើងថា ព្រះប្រាប់ទៅជនជាតិយូដាថា ទ្រង់មានផែនការដ៏ល្អសំរាប់ពួកគេ ហើយថាពួកគេនឹងមានអនាគតល្អនិងមានក្តីសង្ឃឹម។ ព្រះមានបន្ទូលថាជនជាតិយូដានឹងបានត្រឡប់ទៅផ្ទះវិញ ហើយទ្រង់បានមានបន្ទូលទៀតថា ទ្រង់នឹងប្រទានឲ្យគ្រប់យ៉ាងដែលពួកគេធ្លាប់មានពីមុន! សាកស្រមៃបន្តិចមើលថាជនជាតិយូដាមានអារម្មណ៍បែបណា ពេលដែលពួកគេអាចត្រឡប់ទៅផ្ទះរបស់ពួកគេវិញ បន្ទាប់ពីបានរស់នៅកន្លែងដែលគេចាប់ធ្វើជាឈ្លើយអស់រយៈពេល៧០ឆ្នាំជាងនោះ។ ពួកគេបានសរសើរដំកើងព្រះ ហើយអរព្រះគុណព្រះដែលបានអត់ទោសឲ្យពួកគេ និងស្រឡាញ់ពួកគេ។

សេចក្តីស្រឡាញ់របស់ព្រះសំរាប់យើងគឺគ្រប់ល័ក្ខ ហើយជ្រាលជ្រៅ។ ទោះបីជាយើងបះបោរ និងមិនស្តាប់បង្គាប់ព្រះក៏ដោយ យើងអាចប្រាកដថាព្រះចង់ស្តារពួកយើងឡើងវិញ ហើយប្រទាននូវការល្អៗដល់យើងផងដែរ។ ព្រះមានផែនការល្អសំរាប់យើង ក៏ដូចជាទ្រង់មានផែនការល្អសំរាប់ជនជាតិយូដាអញ្ចឹងដែរ។ យើងអាចមានអំណរដោយដឹងថាផែនការរបស់ព្រះនឹងប្រទានឲ្យយើងមានក្តីសង្ឃឹម និងមានអនាគតល្អ។

## ៦. សំនួរពិភាក្សា

១. តើព្រះបានប្រទានអ្វីឲ្យជនជាតិយូដាដើម្បីជួយរក្សាពួកគេឲ្យគេចចេញពីការសំរេចចិត្តខុស?
*ព្រះបានប្រទានច្បាប់ឲ្យពួកគេ*

២. តើជនជាតិយូដាបានធ្វើអ្វីខ្លះជាមួយនឹងច្បាប់ទាំងអស់នោះ?
*ពួកគេមិនបានធ្វើតាមច្បាប់ទាំងអស់នេះទេ ហើយក៏មិនស្ដាប់បង្គាប់ព្រះដែរ*

៣. តើអ្វីជាការដាក់ទោសសំរាប់ការដែលមិនគោរពតាមច្បាប់ និងមិនស្ដាប់បង្គាប់ព្រះ?
*បាប៊ីឡូនបានចូលមកហើយចាប់យកមនុស្សជាច្រើនធ្វើជាឈ្លើយ*

៤. តើព្រះមានផែនការល្អអ្វីខ្លះសំរាប់ពួកគេ ទោះបីជាពួកគេមិនស្ដាប់បង្គាប់ទ្រង់ក៏ដោយ?
*ផែនការរបស់ព្រះសំរាប់ពួកគេគឺនាំពួកគេទៅស្រុកយូដាវិញ បន្ទាប់ពីបានធ្វើជាឈ្លើយអស់រយៈពេល៧០ឆ្នាំ ហើយធ្វើឲ្យពួកគេរីកចំរើនជាមួយសេចក្ដីសង្ឃឹម និងមានអនាគត*

៥. តើអ្នកគិតថាព្រះមានផែនការល្អអ្វីខ្លះសំរាប់អ្នក? *ទុកឲ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «ព្រះគម្ពីរ»

**សម្ភារៈដែលត្រូវការ៖** ហ្វីត ឬដីស



ព្រះគម្ពីរ សញ្ញាថ្មី

ព្រះគម្ពីរ សញ្ញាចាស់

១. គ្រូត្រូវគូររូបប្រអប់ធំៗពីរនៅលើឥដ្ឋដោយប្រអប់មួយសរសេរថា “ព្រះគម្ពីរសញ្ញាថ្មី” និង “ព្រះគម្ពីរសញ្ញាចាស់” នៅក្នុងប្រអប់មួយទៀត។

២. ឲ្យកុមារឈរនៅចន្លោះប្រអប់ទាំងពីរ

៣. គ្រូត្រូវជ្រើសរើស ១០កណ្ឌ ពីព្រះពម្ពីរសញ្ញាចាស់ និង១០កណ្ឌសញ្ញាថ្មី គ្រូត្រូវប្រាប់កណ្ឌគម្ពីរ ដែលគាត់បានរើសមកនោះ ថាវាដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់ ឬសញ្ញាថ្មី។

៤. ប្រសិនបើគ្រូនិយាយឈ្មោះកណ្ឌគម្ពីរមកពីសញ្ញាចាស់ កុមារត្រូវលោតទៅកាន់ប្រអប់សញ្ញាចាស់ និងនិយាយថា “ព្រះគម្ពីរសញ្ញាចាស់”។ ប្រសិនបើគ្រូនិយាយឈ្មោះកណ្ឌគម្ពីរមកពីសញ្ញាថ្មី កុមារត្រូវលោតទៅកាន់ប្រអប់សញ្ញាថ្មី និងនិយាយថា “ព្រះគម្ពីរសញ្ញាថ្មី”។

៥. ប្រសិនបើកុមារលោតខុសប្រអប់នោះគេនិងចាញ់ល្បែងនេះ។

៦. លេងល្បែងនេះរហូតនៅសល់កុមារតែ ៣ ទៅ ៥នាក់ជាអ្នកឈ្នះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ផែនការល្អៗរបស់ព្រះគឺមានសរសេរនៅក្នុងព្រះគម្ពីរទាំងអស់។ សូមចាំថាព្រះតែងតែមានផែនការល្អសម្រាប់អ្នកជានិច្ច!

## ៨. ខគម្ពីរចងចាំ យេរេមា ២៩:១១

## ៩. ហត្ថកម្ម ផាត់ពណ៌រូបភាព “ព្រះមានផែនការល្អសំរាប់យើង”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះមានផែនការល្អសំរាប់យើង

